**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៤ ៧៨៦នាក់ នៃរោងចក្រ សហគ្រាស ទាំង១៩ នៃវិស័យកាត់ដេរ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលត្រូវបានការព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីជុំទី១នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាស នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្រោយការបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញទន់ ក្នុងនោះចំនួន៖

- ១៥២ ០០០រៀល (៣៨ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ៤៤ថ្ងៃ
- ៣០៤ ០០០រៀល (៧៦ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៥១ថ្ងៃ ឡើងទៅ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង១៩ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
### គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ**
**ចំនួន ១៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 1 | ក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហាយ សេង ១៦៨ (ខេមបូឌា) ហ្គាមិន ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ម៉នីង គ្លរី ហ្គាមេន អេនធើប្រាយ | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ខូ ហឺស្ត (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន សាមីល ខេមបូ ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ស៊ីធីល (ខេមបូឌា) ហ្គាមិន មេនូហ្វេកឌីរីង ខូអិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ស៊ុព្រីមៀរ ធូ (ខេមបូឌា) និងសាខា | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ហ៊ីលថប ឡាក់ហ្គេដ (ខេមបូឌា) ឯ.ក | កណ្ដាល |
| 11 | ក្រុមហ៊ុន ស៊ីគ្គូ (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន ហ្វាស ម៉េកឃីង ឯ.ក | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ហ៊ីរ៉ូតា ( ខេមបូឌា) ហ្គាមិន | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន វេនធូរ៉ា លេដីវែរ អឹមអែហ្វា៉យ (ស៊ីឌី) ឯ.ក | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន សាញនីង (ខេមបូឌា) ប៉ែល&ប៉ែក ឯ.ក | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ទ្រីនីធីហ៊ែនប៉ែក.ខូ.អិលធីឌី | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ញូអេធីធីស៊ូម៉េកឃីង ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន យូលី អ៊ិនធើណេសិនណល (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | ស្វាយរៀង |
| 19 | ក្រុមហ៊ុន ស័ង លី (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | ស្វាយរៀង |